# គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា



## សាវតា

ថ្វីត្បិតតែប្រព័ន្ធអប់រំនៅកម្ពុជាមានការរីកចម្រើន និងទទួលបាននូវសមិទ្ធិផលជាច្រើន តាមរយៈកំណែទម្រង់វិស័យអប់រំ និងកំណើនវិនិយោគរបស់រាជរដ្ឋាភិបាលលើវិស័យអប់រំ តាំងពីឆ្នាំ២០០១មកក៏ដោយ ក៏ការប្រឈមដ៏គួរឱ្យកត់សម្គាល់មួយចំនួននៅតែមាន ទាក់ទងទៅនឹងភាពងាយស្រួលចូលសាលារៀន (អត្រាចូលរៀន) និងគុណភាពអប់រំ។ ករណីនេះកើតឡើងជាពិសេស ចំពោះកុមារដែលរស់នៅតំបន់ជនបទដាច់ស្រយាល និងកុមារដែលងាយរងគ្រោះ រួមមានកុមារក្រីក្រ កុមារជនជាតិភាគតិច និងកុមារី។ គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា (IBECP) ដែលឧត្ថម្ភគាំទ្រដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក (USAID) ព្យាយាមដោះស្រាយបញ្ហាទាក់ទងនឹងអត្រាចូលរៀន និងគុណភាពអប់រំ តាមរយៈយុទ្ធវិធីដែលផ្ដោតទៅលើការអភិវឌ្ឍកម្មវិធីគ្រប់វិស័យ ការអភិវឌ្ឍដែលដឹកនាំដោយអ្នកពាក់ព័ន្ធ ការកែលម្អការអប់រំដែលឆ្លើយតបទៅនឹងការរស់នៅក្នុងមូលដ្ឋាន និងការគ្រប់គ្រង។ គម្រោងនេះ ត្រូវបានរៀបចំឡើងដោយផ្អែកតាមបទពិសោធន៍ ល្អៗដែលទទួលបានពីគម្រោងគាំទ្រសេវាអប់រំសម្រាប់កុមារនៅតំបន់ដាច់ស្រយាល (ESCUP) និងគម្រោងសាលារៀនដើម្បីជីវិតរបស់អង្គការអប់រំពិភពលោក ដែលទទួលថវិកាពី USAID ក្នុងរយៈពេលប្រាំឆ្នាំកន្លងមក។ គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា ចាប់ផ្ដើមពីខែតុលា ឆ្នាំ ២០០៩ ហើយត្រូវបានរំពឹងទុកថា នឹងបន្តរហូតដល់ខែកញ្ញា ឆ្នាំ ២០១៤។



## គោលបំណង និងទិសដៅកម្មវិធី

គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា ត្រូវបានរៀបចំឡើងក្នុងគោលបំណងកែលម្អ "ការអប់រំយុវវ័យឱ្យកាន់តែប្រសើរ" លើកកម្ពស់គុណភាពអប់រំដើម្បីឆ្លើយតបទៅនឹងជីវភាពរស់នៅក្នុងមូលដ្ឋាន និងបង្កើនភាពងាយស្រួល-ចូលសាលារៀន"។ ការបង្កើនភាពងាយស្រួលចូលសាលារៀនត្រូវបានឆ្លើយតប តាមរយៈអន្តរាគមន៍ជាច្រើនរួមគ្នា ពោលគឺកម្មវិធីអាហារូបករណ៍ ការសង់បង្គន់អនាម័យនិងការផ្ដល់ទឹកស្អាត នៅតាមសាលារៀន ព្រមទាំងសកម្មភាពមួយ ចំនួនទៀត-ដែលជម្រុញការចូលរៀន ដោយប្រើកញ្ចប់ថវិកាសាលារៀន។ ទិសដៅក្នុងការលើកម្ពស់គុណភាពអប់រំនឹងត្រូវឆ្លើយតប តាម-រយៈអន្តរាគមន៍ដែលផ្ដោតទៅលើកម្មវិធីសិក្សាបំណិនជីវិត កម្មវិធីបំប៉នគ្រូ និង ការគ្រប់គ្រងសាលារៀន។ គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា នឹងផ្ដោតទៅលើសាលារៀននៅតំបន់ទីប្រជុំជន ជនបទ និងតំបន់ដាច់ស្រយាល។ គម្រោងនឹងកំណត់ដោយច្បាស់សាល់នូវគុណភាពអប់រំទាក់ទងនឹងការប្រកបមុខរបរទៅអនាគត ការត្រៀមរកការងារធ្វើ និងបំណិនជីវិតផ្សេងៗទៀត ជាពិសេសផ្នែកកសិកម្ម។ គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា ព្យាយាមផងដែរ ក្នុងការពង្រឹងសមត្ថភាពសង្គមស៊ីវិល មន្ត្រីថ្នាក់មូលដ្ឋាន និងអង្គការដៃគូ ។ ជាផ្នែកមួយនៃគម្រោងផងដែរនោះ ដៃគូមូលដ្ឋាននឹងទទួលបានការកសាងសមត្ថភាពដើម្បីសម្រេចបាននូវការទទួលស្គាល់ជាផ្លូវការ ហើយដែលធ្វើឱ្យពួកគេ អាចនឹងស្វែងរកថវិកាដោយផ្ទាល់ពីម្ចាស់ជំនួយ ទាំងពហុភាគី និង ទ្វេភាគី ដូចជា USAID ជាដើម។

## ដៃគូរបស់កម្មវិធី



គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា ធ្វើការជាដៃគូជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (អង្គការខេប) និងក្រសួងអប់រំ យុវជន និងកីឡា។ អង្គការអប់រំពិភពលោក បានយកចិត្តទុកដាក់ជាយូរមកហើយ លើការចូលរួមរបស់ដៃគូនានា និងអង្គការដៃគូក្នុងស្រុក (រួមមាន ដូចជាអង្គការ WCRD, BDSA និង KWA) តាមរយៈរចនាសម្ព័ន្ធក្រុមការងារថ្នាក់ខេត្ត។ ការងារទាំងនេះ រួមមានតំណាងមន្ទីរអប់រំ យុវជន និង កីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាស្រុក កម្រងសាលារៀន និងនាយកសាលា។ ក្រុមពិគ្រោះយោបល់ ថ្នាក់ជាតិ ត្រូវបានរៀបចំនិងមានការចូលរួមពីថ្នាក់នាយកដ្ឋានពាក់ព័ន្ធ ដើម្បីរួមចំនែកអនុវត្តគម្រោងនេះ។ បន្ថែមពីនេះទៀត អង្គការអប់រំពិភពលោក បានបង្កើតភាពជាដៃគូជាមួយអង្គការអន្តរជាតិ ចំនួនពីរទៀត គឺអង្គការ Equal Access និង វិទ្យាស្ថានស្រាវជ្រាវអាមេរិក (AIR) សម្រាប់កម្មវិធីពិសេស។

## តំបន់គោលដៅ និងអ្នកទទួលផល

អង្គការអប់រំពិភពលោក និងដៃគូរបស់ខ្លួន នឹងធ្វើការនៅក្នុងខេត្តបី គឺ ខេត្តកំពង់ចាម ក្រចេះ និង សៀមរាប។ សាលាគោលដៅ រួមមានសាលារៀននៅតំបន់ទីប្រជុំជន ជនបទ និង តំបន់ដាច់ស្រយាល។ គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា នឹងជួយសិស្សគោលដៅ ក្នុងចំនួនទ្វេដង បើធៀបទៅនឹងគម្រោងអេស្កាប់ និង គម្រោងសាលារៀនដើម្បីជីវិត ពោលគឺប្រមាណជា ១០០. ០០០ នាក់ នៅសាលាបឋមសិក្សា និងមធ្យមសិក្សា ។



## យុទ្ធវិធី

សម្មតិកម្មអភិវឌ្ឍន៍ ក្នុងគោលដៅរបស់គម្រោង IBECP គឺដើម្បីឱ្យសិស្សទទួលបានការអប់រំកម្រិតមូលដ្ឋានមួយដែលឆ្លើយតបទៅនឹងជីវិតរស់នៅប្រកបដោយគុណភាព ដែលជាការដោះស្រាយទៅលើប្រឈមទាំងពីរផ្នែក គឺកត្តាតម្រូវការ និងកត្តាផ្គត់ផ្គង់ តាមយុទ្ធវិធីផ្តល់អំណាចទៅឱ្យអ្នកពាក់ពន្ធ័ និងការកសាងភាពជាម្ចាស់។ បញ្ហាប្រឈមទាំងនេះ តែងតែមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក និងពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងៗទៀត យោងទៅតាមបរិបទមូលដ្ឋាន។ ដូចនេះ ការប្រតិបត្តិគម្រោង គឺត្រូវតែផ្អែកទៅលើយុទ្ធវិធីអភិវឌ្ឍគ្រប់វិស័យ ដែលមានភាពបត់បែនគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងការផ្លាស់ប្តូរ ដែលកំណត់ដោយអ្នកពាក់ពន្ធ័នៅមូលដ្ឋានផង ព្រមទាំងស្របទៅនឹងគោលនយោបាយថ្នាក់ជាតិ ផងដែរ។

### រចនាសម្ព័ន្ធកម្មវិធី និង អន្តរាគមន៍

គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា ចែកចេញជា៤ផ្នែកសំខាន់ៗ:

១, ការកសាងសមត្ថភាពដល់អង្គការក្នុងស្រុក និង មន្ត្រីមូលដ្ឋាន ព្រមទាំងការស្វែងរកការគាំទ្រដើម្បីនិរន្តរភាព។

២, លើកកម្ពស់សមធមិក្នុងការទទួលសេវាអប់រំ:
- កម្មវិធីអាហារូបករណ៏
- ការផ្តល់កញ្ចប់ថវិកាដល់សាលារៀន

៣, លើកកម្ពស់ការគ្រប់គ្រងសាលា និង បង្កើនការចូលរួមរបស់សហគមន៏

៤, ការអប់រំដែលមានការពាក់ពន្ធ័នឹងជីវភាពរស់នៅ:
- កម្មវិធីបំណិនជីវិត
- កម្មវិធីបំប៉នគ្រូ

### ការកសាងសមត្ថភាព និងការស្វែងរកការគាំទ្រ ដើម្បីអោយមាននិរន្តរភាព

- ផ្តល់វិញ្ញាបនប័ត្រដល់អង្គការដៃគូក្នុងស្រុក ដោយអង្គការទទួលស្គាល់ការគ្រប់គ្រង
- ការផ្សព្វផ្សាយកម្មវិធីតាមវិទ្យុ
- សិក្ខាសាលាថ្នាក់ជាតិ ដើម្បីផ្សព្វផ្សាយកម្មវិធីសិក្សាស្តីពីបំណិនជីវិត

### សមធម៏ក្នុងការបង្កើនការចូលរៀន

- អំណោយសាលារៀន (ឧ. បំប៉នសិស្សរៀនយឺត ការគាំទ្របណ្ណាល័យ ការធ្វើការជាមួយជនជាតិ-ភាគតិច ការគូរផែនទីសាលារៀន ។ល។)
- អាហារូបករណ៏សម្រាប់សិស្សងាយរងគ្រោះ
- ការជ្រើសរើសគ្រូពីមូលដ្ឋាន និងការផ្តល់អាហារូបករណ៏ដល់គរុសិស្ស
- ការគាំទ្រគ្រូសហគមន៏
- ការព្យាបាលសុខភាពដល់កុមារ
- ការរៀបចំប្រពន្ធ័ទឹក បង្គន់អនាម័យ និងហេដ្ឋារចនាសម្ពន្ធ័សាលារៀន

### អន្តរាគមន៏ផ្នែកបំណិនជីវិត និងការបំប៉នគ្រូ

- បំណិនជីវិតទាក់ទងនឹងជីវភាពរស់នៅជាក់ស្តែង
- បំណិនជីវិតទាក់ទងនឹងការត្រៀមរកការងារធ្វើ
- បំណិនជីវិតទាក់ទងនឹងវប្បធមិ និងសង្គម
- បំណិនទូទៅតាមរយៈការបង្រៀន និងរៀន
- ការអប់រំស្តីពីសុខភាព
- ការបង្កើតបន្ទប់សិក្សាកុំព្យូទ័រ និងបន្ទប់ពិសោធន៏វិទ្យាសាស្រ្ត


### ទំនាក់ទំនងព័តិមាន

Kurt Bredenberg, ប្រធានគម្រោង

អង្គការអប់រំពីភពលោក នៅកម្ពុជា

kbredenberg@worlded.org.kh

Tel: (855) 012 963 353